# អង្កេតស្ដីពីសមត្ថភាព និងការត្រៀមខ្លួនរបស់ឃុំក្នុងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍មូលដ្ឋានៈ លទ្ធផលបឋម[១]

## ១. សេចក្ដីផ្ដើម

ទិដ្ឋភាពដ៏សំខាន់មួយនៃកំណែទម្រង់វិមជ្ឈការ គឺការផ្ដល់ក្របខ័ណ្ឌមួយដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីគ្រប់គ្រងនិងសម្របសម្រួលគម្រោងអភិវឌ្ឍន៍ និងគំនិតផ្ដួចផ្ដើមនានានៅមូលដ្ឋាន។ ការវិភាគពីគម្រោងផ្ដល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១២ បង្ហាញថា ៧៧% នៃការអនុវត្តគម្រោង ជាការទទួលខុសត្រូវរួមគ្នារបស់អាជ្ញាធរថ្នាក់ក្រោមជាតិ និងរដ្ឋាភិបាលថ្នាក់ជាតិ។ យុទ្ធសាស្ត្រជាដៃគូរបស់កម្ពុជាជាមួយ ADB ភាគច្រើនផ្ដោតលើសហគមន៍ក្នុងអាងទន្លេសាប (ADB 2009; Tariq 2011)។

ក្រុមប្រឹក្សាឃុំ ដែលជាស្ថាប័នរដ្ឋាភិបាលថ្នាក់ក្រោមជាតិចំបងមួយ បាននិងកំពុងបន្តទទួលខុសត្រូវក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ ដើម្បីកែលម្អជីវភាពរស់នៅនៃសហគមន៍មូលដ្ឋានក្នុងព្រំដែនរដ្ឋបាលរបស់ខ្លួន។ ដូច្នេះ ការយល់ដឹងកាន់តែស៊ីជម្រៅពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ និងបទពិសោធន៍ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ និងគំនិតផ្ដួចផ្ដើមផ្សេងៗ អាចជួយកែលម្អការកំណត់គោលដៅគម្រោងអភិវឌ្ឍន៍សម្រាប់ប្រជាជនធម្មតា។

អត្ថបទនេះ បង្ហាញពីវិធីសាស្ត្រជាក់ស្ដែងសម្រាប់ការចាត់ថ្នាក់សមត្ថភាពឃុំ ក្នុងការគ្រប់គ្រង និងអនុវត្តគម្រោងអភិវឌ្ឍន៍នៅមូលដ្ឋាន។ ពាក្យ "សមត្ថភាពឃុំ" មិនត្រឹមតែសំដៅលើអត្ថិភាពនៃហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងសម្រួលការងាររបស់ឃុំប៉ុណ្ណោះទេ តែថែមទាំងសំដៅលើសមត្ថភាព និងការអនុវត្តរបស់សមាជិកក្រុមប្រឹក្សាឃុំផងដែរ។

## ២. កត្តានានាសម្រាប់ការចាត់ថ្នាក់សមត្ថភាពឃុំ

ការសិក្សាជាច្រើនស្ដីពី វិមជ្ឈការ និងវិសហមជ្ឈការ ផ្ដល់នូវចំណេះដឹងជារួម អំពីរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាល មុខងារ សមត្ថភាព និងការរួមចំណែករបស់ក្រុមប្រឹក្សាឃុំទាក់ទងនឹងការអភិវឌ្ឍ និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ព្រមទាំងបានគូសបញ្ជាក់ពីបញ្ហាប្រឈមជាច្រើន និងដំណោះស្រាយជាយុទ្ធសាស្ត្រនានា។

ធនធានធម្មជាតិ មានជាអាទិ៍ ទឹក ត្រី និងព្រៃឈើ ជាប្រភពសំខាន់នៃជីវភាពរស់នៅ និងប្រាក់ចំណូលសម្រាប់ប្រជាជនក្នុងតំបន់ភូមិសាស្ត្រដូចជានៅអាងទន្លេសាបនេះ។ ប៉ុន្តែបទពិសោធន៍និងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្នុងការគ្រប់គ្រង និងលៃចែកធនធានធម្មជាតិឲ្យមានសមធម៌ និងមានចីរភាព គឺនៅមានកម្រិត។ Rusten *et at.* (2004) អះអាងថា ក្រុមប្រឹក្សាឃុំនៅខ្វះចំណេះដឹង និងការយល់ច្បាស់អំពីរបៀបគ្រប់គ្រងធនធានធម្មជាតិ រីឯ Kim & Henke (2005) បានបញ្ជាក់ថា ក្រុមប្រឹក្សាឃុំកំពុងជួបប្រទះបញ្ហាប្រឈមយ៉ាងធំ ក្នុងការការពារធនធានធម្មជាតិ។ ការសិក្សាមួយនាពេលថ្មីៗធ្វើឡើងដោយ Thon *et al.* (2009) សន្និដ្ឋានថា សមត្ថភាពគ្រប់គ្រងធនធានធម្មជាតិរបស់ក្រុមប្រឹក្សាឃុំ ត្រូវតែពង្រឹងថែមទៀត ហើយការគ្រប់គ្រងធនធានធម្មជាតិនៅកម្រិតតំបន់ គួរមានទំនាក់ទំនងប្រសើរជាងមុនជាមួយរដ្ឋាភិបាលមជ្ឈិម។

ការរចនារៀបចំគម្រោងអភិវឌ្ឍន៍នៅមូលដ្ឋានដោយមានការចូលរួម ក្នុងនេះមានទាំងការធ្វើផែនការ និងគម្រោងថវិកាផង គឺសំដៅបំផុស និងជម្រុញឲ្យសហគមន៍ចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។ ទោះយ៉ាងនេះក្ដី គណៈកម្មាធិការរៀបចំផែនការ និងថវិកា នៅទន់ខ្សោយនៅឡើយ ហើយទំនងមានសមាជិកតែពីរបីនាក់ប៉ុណ្ណោះដែលសកម្មនឹងការងារ (Kim & Henke 2005)។ ហិរញ្ញប្បទានមានកម្រិត និងក្របខ័ណ្ឌពេលវេលាជាក់លាក់ អាចជម្រុញឲ្យក្រុមប្រឹក្សាឃុំធ្វើការកំណត់អាទិភាពមុនពេលបានពិគ្រោះជាមួយអ្នកភូមិ ឬដាក់ចេញនូវផែនការសកម្មភាពឲ្យស្របតាមបំណងរបស់អ្នកផ្ដល់ជំនួយ ជាជាងតាមអាទិភាពរបស់អ្នកភូមិ។ ចំពោះគុណភាពនៃការពិគ្រោះយោបល់វាអាស្រ័យលើសមត្ថភាពរបស់គណៈកម្មាធិការ ហើយក៏អាស្រ័យលើសមត្ថភាពរបស់សមាជិកគណៈកម្មាធិការម្នាក់ៗដែរ។

គម្រោងអភិវឌ្ឍន៍មូលដ្ឋាន ទទួលបានហិរញ្ញប្បទានពីមូលនិធិឃុំ/សង្កាត់ និងប្រភពពីខាងក្រៅផ្សេងទៀត ដូចជាបុគ្គល និងគណបក្សនយោបាយនានា (Thon *et al.* 2009)។ ដូច្នេះ ឃុំត្រូវតែឆ្លើយតបនឹងគោលដៅដែលបានព្រមព្រៀងជាមួយម្ចាស់ជំនួយ ហើយនេះជាបញ្ហាប្រឈមមួយ។

សរុបមក មានកត្តាជាច្រើន ដែលកំណត់ពីសមត្ថភាពនៃការអនុវត្តមុខងារ និងទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ ក៏ដូចជាគុណភាព និងបរិមាណនៃលទ្ធផលសម្រេចបាន។ សមត្ថភាពសំដៅដល់លទ្ធភាពក្នុងការអនុវត្តមុខងារឲ្យបានសក្តិសិទ្ធិ មានប្រសិទ្ធភាព និងមានចីរភាព ហើយសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ក្នុងរយៈពេលកំណត់ណាមួយ (Blagescu & Young 2006; Em 2008)។ ដូច្នេះ សមត្ថភាពក្រុមប្រឹក្សាឃុំ ត្រូវជាប់ទាក់ទិនទាំងធនធាន និងប្រព័ន្ធរបស់ឃុំ ក្នុងនេះមានទាំងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំផងដែរ។ ការសិក្សាបានរកឃើញកត្តា ១០ ដែលកំណត់លើសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សា។

---

១ អត្ថបទនេះ រៀបចំដោយលោក អែម សូ៉ានី និងលោក គឹម សួ ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។ អត្ថបទនេះ សង្ខេបរបាយការណ៍ស្ដីពី អង្កេតសមត្ថភាព និងការត្រៀមខ្លួនរបស់ឃុំ (Em & Kim 2011)។ អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ មូលនិធិជប៉ុនសម្រាប់ការកាត់បន្ថយភាពក្រីក្រ ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា ដែលបានផ្ដល់ហិរញ្ញប្បទាន និងចំពោះលោក កុយ រ៉ា និងលោក អ៊ុច ឈួង ដែលបានជួយក្នុងការធ្វើអង្កេត។

**ភាពក្រីក្រ៖** អត្រានៃភាពក្រីក្រ បង្ហាញពីបញ្ហាប្រឈមក្នុងការអភិវឌ្ឍ ជាពិសេសដើម្បីសម្រេចបានការកាត់បន្ថយភាពក្រីក្រ ១% ក្នុងមួយឆ្នាំ ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ (RGC 2008)។ តួលេខនៃភាពមិនក្រ ត្រូវកំណត់ឡើងដោយយក ១០០ ដកជាមួយនឹងអត្រានៃភាពក្រីក្រ។ អត្រាទាបនៃភាពមិនក្រ បង្ហាញថា ភាពក្រីក្រ និងភាពងាយរងគ្រោះខ្លាំង នៅមានកម្រិតខ្ពស់ ហើយធាតុផ្សំមួយចំនួន ដូចជា ប្រាក់ចំណូល ប្រភពដោះស្រាយជីវភាព និងសន្តិសុខស្បៀង ជាដើម ត្រូវតែពង្រឹងឡើង និងធ្វើពិពិធកម្ម។

**ទីតាំងភូមិសាស្ត្រ៖** ទីតាំងឃុំនៅដាច់ឆ្ងាយពីផ្លូវធំ ធ្វើឲ្យការដឹកជញ្ជូនកសិផលទៅទីផ្សារ និងការសម្របសម្រួលសកម្មភាពគាំទ្រពីខាងក្រៅ ជួបការលំបាក និងត្រូវចំណាយអស់ច្រើន។

**សាលាឃុំ៖** ជាគោលការណ៍ ក្រុមប្រឹក្សាឃុំ គឺជាមជ្ឈមណ្ឌលនៃសេវាសាធារណៈ គំនិតផ្តួចផ្តើម និងការពិភាក្សានៅមូលដ្ឋាន ហើយការគ្រប់គ្រងសកម្មភាពទាំងនេះ ត្រូវមានកន្លែងការិយាល័យសមរម្យ។

**គ្រឿងសម្រួលការងារ៖** បរិក្ខារ និងគ្រឿងសង្ហារឹមមូលដ្ឋាន សម្រាប់ប្រើក្នុងការិយាល័យ សំខាន់ខ្លាំងណាស់សម្រាប់បម្រើសកម្មភាព និងសេវាសម្របសម្រួលរបស់ឃុំ។ តួយ៉ាង ការមានទូគ្រប់គ្រាន់សម្រាប់រក្សាឯកសារ និងកំណត់ត្រាផ្សេងៗឲ្យបានត្រឹមត្រូវ អាចជួយសម្រួលឲ្យការផ្តល់សេវាអនុវត្តបានកាន់តែឆាប់រហ័ស។

**កិច្ចប្រជុំ៖** សមាជិកក្រុមប្រឹក្សាឃុំធ្វើសេចក្តីសម្រេចដោយមានការចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ដែលតាមធម្មតា ត្រូវធ្វើប្រចាំខែ។ កិច្ចប្រជុំប្រចាំខែ ការពិគ្រោះយោបល់ និងកិច្ចប្រជុំចំពោះកិច្ចផ្សេងៗ ជាទូទៅត្រូវធ្វើឡើងនៅសាលាឃុំ។ កំណត់ត្រាពីកិច្ចប្រជុំ ត្រូវផ្ញើជូនទៅការិយាល័យថ្នាក់លើទៀត។ ការពិគ្រោះយោបល់ជាញឹកញាប់ និងជាប្រព័ន្ធ ដោយមានការចូលរួមយ៉ាងសកម្ម និងមានកំណត់ត្រាត្រឹមត្រូវ ផ្តល់នូវអារម្មណ៍ថា ការសម្រេចចិត្តមានលក្ខណៈរាប់បញ្ចូលល្អ។

**ប្រព័ន្ធហិរញ្ញវត្ថុ៖** សមាជិកក្រុមប្រឹក្សាឃុំ មានលទ្ធភាពទទួលបានប្រភពហិរញ្ញប្បទានច្រើន។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ ឆ្លុះបញ្ចាំងពីគណនេយ្យភាពរបស់ឃុំចំពោះអ្នកផ្តល់មូលនិធិ។ យ៉ាងហោចណាស់មានយន្តការហិរញ្ញវត្ថុពីរ ដែលឃុំបានទទួលយកមកប្រើប្រាស់ គឺយន្តការរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DoLA) និងយន្តការរបស់ទីភ្នាក់ងារផ្តល់មូលនិធិ។ ប៉ុន្តែគួរកត់សម្គាល់ថា ទីភ្នាក់ងារផ្តល់មូលនិធិផ្សេងៗគ្នា មានប្រព័ន្ធហិរញ្ញវត្ថុខុសៗគ្នា។

**ការរៀបចំគម្រោង និងផ្តល់មូលនិធិ៖** ការរចនារៀបចំគម្រោងដោយមានការចូលរួមសម្រាប់គំនិតផ្តួចផ្តើមអភិវឌ្ឍន៍នៅមូលដ្ឋានអនុវត្តឡើង តាមរយៈការពិគ្រោះយោបល់ជាមួយអ្នកភូមិ ដើម្បីឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋាន។ ការកំណត់អាទិភាពនៃសកម្មភាពនានាក្នុងផែនការវិនិយោគរបស់ឃុំ គឺជាលទ្ធផលនៃការពិគ្រោះយោបល់ថ្នាក់មូលដ្ឋាន។

**បរិស្ថាន និងសហគមន៍៖** ជាការសំខាន់ណាស់ដែលសមាជិកក្រុមប្រឹក្សាមានការយល់ដឹងពី ផលប៉ះពាល់បរិស្ថាន និងបម្រែបម្រួលអាកាសធាតុ។ ចំណេះដឹងនេះជួយសម្រួលពួកគេក្នុងការបង្កើតគំនិតផ្តួចផ្តើម និងកំណត់អាទិភាពដែលអំណោយផលដល់បរិស្ថាននៅមូលដ្ឋាន។ ផែនការវិនិយោគរបស់ឃុំ រំពឹងថាមានបូកបញ្ចូលនូវកត្តាសង្គមមួយចំនួន ជាអាទិ៍ ការដោះស្រាយទំនាស់ សមភាពយេនឌ័រ ការចូលរួមរបស់ក្រុមគ្មានសិទ្ធិអំណាច ដូចជាជនជាតិដើមភាគតិច អ្នកផ្ទុកមេរោគអេដស៍ ។ល។

**បុគ្គលិកជំនួយការ៖** ទោះជាគោលការណ៍ សមាជិកក្រុមប្រឹក្សាជាប់ឆ្នោត ត្រូវមានចំនួនគ្រប់គ្រាន់សម្រាប់ធ្វើជាតំណាងឲ្យប្រជាជនក្នុងឃុំទាំងមូលក្តី ក៏ការផ្តល់សេវាជាក់ស្តែង និងការពិគ្រោះយោបល់អំពីគម្រោងអភិវឌ្ឍន៍នានា វាប្រែប្រួលខុសគ្នាដែរ។ បុគ្គលិកមានសមត្ថភាព និងបទពិសោធន៍សម្រាប់បំពេញតួនាទីជំនួយការ អាចជ្រើសរើសបានតាមរយៈការជួល ការស្ម័គ្រចិត្ត និងការបញ្ជូនមកធ្វើការបណ្តោះអាសន្ន។

**ធនធានមនុស្ស និងការបណ្តុះបណ្តាល៖** ការគ្រប់គ្រងការផ្តល់សេវាកម្ម រំពឹងថានឹងរីកចម្រើនឡើងតាមរយៈការពិគ្រោះយោបល់ និងការចូលរួមក្នុងព្រឹត្តិការណ៍ចែករំលែកចំណេះដឹង និងការបណ្តុះបណ្តាល ហើយតាមរយៈការធ្វើការរួមគ្នា សមាជិកក្រុមប្រឹក្សាកាន់តែមានទំនុកចិត្តលើខ្លួនឯង ក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

## ៣. វិធីសាស្ត្រធ្វើចំណាត់ថ្នាក់

**នីតិវិធីដាក់ពិន្ទុ៖** សំណួរមួយក្រុមតូច ត្រូវបានបង្កើតឡើងសម្រាប់កត្តានីមួយៗ ដែលត្រូវទទួលបានពិន្ទុ ពី 0 ដល់ ១០០។ កត្តាសំខាន់ ត្រូវទទួលបានពិន្ទុខ្ពស់។ ឧទាហរណ៍ សាលាឃុំសង់ពីឥដ្ឋ ទទួលបានពិន្ទុខ្ពស់ជាងសាលាឃុំសង់ពីឈើ។ វិធីសាស្ត្រដាក់ពិន្ទុនេះ អាចប្រើសម្រាប់ប្រៀបធៀបទិដ្ឋភាពជាក់លាក់នានានៃសមត្ថភាពឃុំ (ពោលគឺ កត្តាខ្លះៗ) ឬសន្ទស្សន៍សមត្ថភាពឃុំ (CCI) (ពោលគឺ កត្តាទាំង១០ ខាងលើ) ដើម្បីអាចមានទស្សនៈកាន់តែធំទូលាយ។

**ការគណនាសន្ទស្សន៍៖** សន្ទស្សន៍សមត្ថភាពឃុំ (CCI) ត្រូវគណនាឡើង ដោយយកពិន្ទុសរុបរបស់កត្តាទាំង១០ ចែកនឹង ១០០០ ដែលជាពិន្ទុអតិបរមា (ពិន្ទុ១០០ សម្រាប់កត្តានីមួយៗ)។ ដូច្នេះ CCI ស្ថិតនៅចន្លោះពី 0 ទៅ ១ ដែល 0 តំណាងឲ្យសមត្ថភាពទាបបំផុត និង ១ តំណាងឲ្យសមត្ថភាពខ្ពស់បំផុត។ CCI របស់ឃុំមួយ មានបង្ហាញជាឧទាហរណ៍នៅក្នុងតារាង ១។

**ការជ្រើសរើសឃុំ៖** វិធីសាស្ត្រចាត់ថ្នាក់នេះ អាចប្រើប្រាស់ដើម្បីប្រៀបធៀបឃុំ ដោយផ្អែកលើកត្តាបានជ្រើសរើសទាំង១០ ខាងលើ ប៉ុន្តែក៏គួរសង្កេតពីអន្តរកម្មនៃកត្តាជាប់ទាក់ទិនផងដែរ។ ដូច្នេះ ឃុំជាគោលដៅនៃគម្រោង ៥ របស់ ADB ក្នុងខេត្តចំនួន ៧ ត្រូវបានជ្រើសរើសសម្រាប់អង្កេត។ គម្រោងទាំង៥ គឺមាន៖ គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (TSEMP) គម្រោងជីវភាពរស់នៅប្រកបដោយចីរភាពនៅបឹងទន្លេសាប (TSSLP) គម្រោង អភិវឌ្ឍន៍តំបន់ជនបទនៅវាលទំនាបបឹងទន្លេសាប (TSLRDP) គម្រោងផ្គត់ផ្គង់ទឹក និងអនាម័យនៅតំបន់ជនបទបឹងទន្លេសាប (TSRWSS) និងគម្រោងអភិវឌ្ឍន៍អ្នកកាន់កាប់ដីតូចៗនៅបឹងទន្លេសាប (TSSHDP)។ គម្រោង TSEMP និង

តារាង ១. ប្រព័ន្ធដាក់ពិន្ទុសម្រាប់កត្តាទាំង១០

| | កត្តា | ពិន្ទុជាក់ស្តែង (ក្រោយអង្កេត) |
|---|---|---|
| A | អត្រាមិនក្រក្នុងឃុំ (១០០ - អត្រាភាពក្រីក្រ) | = 100 - 58.2 = 41.8 |
| B | ទីតាំងភូមិសាស្ត្រ | 75 |
| C | សាលាឃុំ | 95 |
| D | គ្រឿងសម្រួលការងាររបស់ឃុំ | 35 |
| E | ការជួបប្រជុំ | 95 |
| F | ប្រព័ន្ធហិរញ្ញវត្ថុ | 90 |
| G | ការរចនារៀបចំគម្រោង និងការផ្តល់មូលនិធិ | 90 |
| H | បរិស្ថាន និងសហគមន៍ | 100 |
| I | បុគ្គលិកជំនួយការឃុំ | 47 |
| J | ធនធានមនុស្ស និងការបណ្តុះបណ្តាល | 44 |
| | CCI = 712.8/1000 | 0.7128 |

តារាង ២. ការជ្រើសរើសឃុំផ្អែកលើគម្រោងមុនៗ

| គម្រោង | ឃុំក្នុងគម្រោងសរុប | ចំនួនកូតាជ្រើសរើស | ឃុំក្នុងគម្រោងដែលបានជ្រើសរើស | ឃុំមានគម្រោងតែមួយ | ឃុំមានគម្រោងច្រើន |
|---|---|---|---|---|---|
| TSSLP (គម្រោងបានបញ្ចប់) | 37 | 6 | 10 | 1 | 9 |
| TSEMP (គម្រោងបានបញ្ចប់) | 92 | 14 | 19 | 1 | 18 |
| TSLRDP (ទើបចាប់ផ្តើម) | 40 | 6 | 31 | 20 | 11 |
| TSSDHP (ជិតចាប់ផ្តើម) | 193 | 30 | 36 | 19 | 17 |
| TSRWSS (ជិតចាប់ផ្តើម) | 40 | 6 | 19 | 3 | 16 |
| ឃុំក្រៅគម្រោង ADB | 230 | 35 | 20 | 0 | 0 |
| សរុប | 632 | 97 | | | |
| ល្មៀងអតិបរមាក្នុងការជ្រើសគំរូតាង៖ ៩,៣៥ % | | | | | |

TSSLP បានបញ្ចប់រួចរាល់ រីឯគម្រោង TSLRDP ទើបចាប់ផ្តើមនាពេលថ្មីៗ ហើយ គម្រោង TSSHDP និង TSRWSS គ្រោងចាប់ផ្តើមនាពេលឆាប់ៗ។ ខេត្តស្ថិតក្នុងគម្រោង គឺមានបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ និង សៀមរាប។ ឃុំក្នុងខេត្តជាមួយគ្នា តែមិនចំគោលដៅរបស់ ADB ក៏ត្រូវបានជ្រើសរើសដែរ សម្រាប់ធ្វើការប្រៀបធៀប។

ក្នុងចំណោម ៦៣២ឃុំ ក្នុង ៧ខេត្តជាប់បឹងទន្លេសាប និងទន្លេមេគង្គ មាន ៤០២ឃុំ ស្ថិតក្នុងគម្រោង ADB និង ២៣០ឃុំនៅក្រៅគម្រោង។ ពីក្នុងចំណោមប្រជាជនសរុប គេបានជ្រើសរើសដោយចៃដន្យ ១៥% ដែលផ្តល់នូវរបាយគំរូតាងដ៏ល្អមួយ ដោយមានល្មៀង ១០% ក្នុងការជ្រើសគំរូតាង ដែលអាចបណ្តាលមកពីការជ្រើសរើសឃុំជាគោលដៅនៃគម្រោង ADB ពីឆ្នាំ២០០៨ ដល់ ២០១០[២]។

ការប្រមូលទិន្នន័យ៖ ការសិក្សានេះទទួលបានព័ត៌មានពី ការពិភាក្សាតាមក្រុមស្នូល (FGDs) ជាមួយមន្ត្រីឃុំ ដោយប្រើបញ្ជីសំណួរមានជម្រើសច្រើន ផ្អែកលើកត្តាបានជ្រើសរើសទាំង១០។ ដើម្បីធានាគុណភាពព័ត៌មាន បានដោះស្រាយឲ្យឃុំនីមួយៗមានសមាជិកក្រុមប្រឹក្សាយ៉ាងហោចណាស់ ៥០% មកចូលរួមក្នុងការពិភាក្សាក្រុមស្នូល។ ក្រុមស្រាវជ្រាវបានកត់ត្រា និងដាក់ពិន្ទុព័ត៌មានទទួលបាន ទុកសម្រាប់ការវិភាគ។[៣]

## ៤. លទ្ធផលស្រាវជ្រាវសំខាន់ៗ

លទ្ធផលចំបងបានពីអង្កេតនេះ គឺសន្ទស្សន៍សមត្ថភាពឃុំ (CCI) ដែលជាសូចនាករគន្លឹះមួយសម្រាប់វាស់វែងសមត្ថភាពរបស់ឃុំជាទូទៅ។ លទ្ធផលសំខាន់មួយទៀត គឺការកំណត់កត្តាទាំង១០ សម្រាប់ស្វែងរកមើលទិដ្ឋភាពជាក់លាក់នៃសមត្ថភាពឃុំ។ តារាង ៣ បង្ហាញពីលទ្ធផលរបស់ ១០ឃុំ ដែលបានពិន្ទុ

២ រូបមន្តជ្រើសគំរូតាងដោយចៃដន្យនៃ n=N/(1+Ne2) (Zulueta & Costales 2006)

៣ សម្រាប់ព័ត៌មានបន្ថែមស្តីពីវិធីសាស្ត្រចាត់ថ្នាក់ និងឧបករណ៍ប្រមូលទិន្នន័យ សូមទាក់ទងលោក អែម ស្ញ៉ានី និងលោក គឹម សួ នៅវិទ្យាស្ថាន CDRI។

តារាង ៣. ឃុំ ១០ ដែលទទួលបានពិន្ទុលើសគេក្នុងពេលអង្កេត ផ្អែកលើកត្តាជ្រើសរើសទាំង១០

| ខេត្ត | ស្រុក | ឃុំ | កត្តា | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | A | B | C | D | E | F | G | H | I | J | CCI |
| បាត់ដំបង | សង្កែ | កំពង់ព្រះ | 69.2 | 90 | 95 | 69 | 90 | 95 | 95 | 85 | 61 | 56 | 0.81 |
| បន្ទាយមានជ័យ | ក្រុងសិរីសោភ័ណ | ព្រះពន្លា | 86.9 | 90 | 70 | 49 | 95 | 100 | 100 | 100 | 42 | 64 | 0.80 |
| ពោធិ៍សាត់ | បាកាន | ស្នាមព្រះ | 64.2 | 90 | 95 | 69 | 100 | 100 | 90 | 100 | 45 | 49 | 0.80 |
| បាត់ដំបង | ថ្មគោល | អូរតាគី | 74.4 | 90 | 95 | 65 | 100 | 100 | 95 | 95 | 19 | 61 | 0.79 |
| កំពង់ចាម | ស្ទឹងត្រង់ | ព្រែកបាក់ | 74.6 | 90 | 95 | 42 | 100 | 95 | 95 | 100 | 39 | 55 | 0.79 |
| ពោធិ៍សាត់ | បាកាន | ត្រពាំងជង | 68.2 | 90 | 85 | 61 | 95 | 100 | 95 | 80 | 59 | 56 | 0.79 |
| ពោធិ៍សាត់ | ក្រគរ | ឈើតុំ | 65.5 | 80 | 95 | 59 | 100 | 100 | 95 | 100 | 42 | 55 | 0.79 |
| កំពង់ចាម | បាធាយ | សំបូរ | 74.3 | 85 | 95 | 47 | 95 | 95 | 95 | 95 | 41 | 54 | 0.78 |
| បន្ទាយមានជ័យ | មង្គលបុរី | បន្ទាយនាង | 70.8 | 90 | 95 | 54 | 95 | 95 | 95 | 85 | 62 | 31 | 0.77 |
| កំពង់ធំ | ស្ទោង | ប្រឡាយ | 61.6 | 90 | 95 | 32 | 95 | 95 | 95 | 90 | 57 | 63 | 0.77 |

A: អត្រាមិនក្រ B: ទីតាំងភូមិសាស្ត្រ C: សាលាឃុំ D: គ្រឿងសម្រួលការងារ E: ការជួបប្រជុំ F: ប្រព័ន្ធហិរញ្ញវត្ថុ
G: ការរចនារៀបចំគម្រោង និងការផ្តល់មូលនិធិ H: បរិស្ថាន និងសហគមន៍ I: បុគ្គលិកជំនួយការឃុំ J: ធនធានមនុស្ស និងការបណ្តុះបណ្តាល

តារាង ៤. ការប្រៀបធៀបកត្តាកំណត់ក្នុងឃុំអង្កេតចំនួនពីរ

| | កត្តាបានអង្កេត | កំពង់ព្រះគគីរ * | កំពង់ព្រះ ** |
|---|---|---|---|
| A | អត្រាមិនក្រ | 59.7 | 69.2 |
| B | ទីតាំងភូមិសាស្ត្រ | 75 | 90 |
| C | សាលាឃុំ | 70 | 95 |
| D | គ្រឿងសម្រួលការងាររបស់ឃុំ | 9 | 69 |
| E | ការជួបប្រជុំ | 90 | 90 |
| F | ប្រព័ន្ធហិរញ្ញវត្ថុ | 90 | 95 |
| G | ការរចនារៀបចំគម្រោង និងការផ្តល់មូលនិធិ | 75 | 95 |
| H | បរិស្ថាន និងសហគមន៍ | 65 | 85 |
| I | បុគ្គលិកជំនួយការឃុំ | 36 | 61 |
| J | ធនធានមនុស្ស និងការបណ្តុះបណ្តាល | 35 | 56 |
| | CCI | 0.6 | 0.81 |

* ឃុំកំពង់ព្រះគគីរ ស្ថិតក្នុងស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង

** ឃុំកំពង់ព្រះ ស្ថិតក្នុងស្រុកសង្កែ ខេត្តបាត់ដំបង

លើសគេ។ CCI ពេញលេញ អាចរកបាននៅក្នុង Em & Kim (2011)។

ដើម្បីបង្ហាញពីការប្រើប្រាស់ CCI មានការប្រៀបធៀបពិន្ទុរវាងឃុំពីរ នៅក្នុងតារាង៤។ ឃុំកំពង់ព្រះគគីរ មានCCI ស្មើនឹង ០,៦ ហើយឃុំកំពង់ព្រះ មាន ០,៨១។ ឃុំកំពង់ព្រះ មានពិន្ទុសរុបលើកត្តាទាំង១០ ខ្ពស់ជាងឃុំកំពង់ព្រះគគីរ គឺមានន័យថា ឃុំកំពង់ព្រះ មានសមត្ថភាពខ្ពស់ជាង ក្នុងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍។

ការចុះពិន្ទុកត្តាទាំង១០ នៅលើគំនូសស្ថិតិរ៉ាដា (ក្រាហ្វិក ១) ធ្វើឲ្យការពិនិត្យមើល និងការប្រៀបធៀប សមត្ថភាពឃុំទាំងពីរកាន់តែងាយស្រួល។

CCI នៃឃុំអង្កេតទាំង ៩៧ គេបានបែងចែកជា ៣ កម្រិត ផ្អែកលើការវិភាគប្រេកង់៖ ខ្ពស់ (CCI ធំជាង ០,៧៤) មធ្យម (CCI នៅចន្លោះពី ០,៧០ ទៅ ០,៧៤) និង ទាប (CCI តូចជាង ០,៧០) ។ ឃុំអង្កេត ជិតដល់ ២៩% មាន CCI ខ្ពស់ ហើយ

ប្រហែល ៤៥% មាន CCI មធ្យម និង ជិតដល់ ២៦% មាន CCI ទាប។

ក្រាហ្វិក ១. ការប្រៀបធៀបសមត្ថភាពរវាង ២ឃុំអង្កេត ដោយប្រើកត្តាជ្រើសរើសទាំង១០




A: អត្រាមិនក្រ B: ទីតាំងភូមិសាស្ត្រ C: សាលាឃុំ D: គ្រឿងសម្រួលការងារ E: ការជួបប្រជុំ F: ប្រព័ន្ធហិរញ្ញវត្ថុ G: ការរៀបចំគម្រោង និងការផ្តល់មូលនិធិ H: បរិស្ថាន និងសហគមន៍ I: បុគ្គលិកជំនួយការឃុំ J: ធនធានមនុស្ស និងការបណ្តុះបណ្តាល

បន្ទាប់ពីគូសផែនទីឃុំដោយប្រើចំណាត់ថ្នាក់ដូចខាងលើ គេអាចឃើញថា ឃុំដែលមានទីតាំងជិតផ្លូវធំ (ផ្លូវជាតិលេខ៥ ឬលេខ៦) ស្ថិតក្នុងក្រុមមានសមត្ថភាពខ្ពស់ និងមធ្យម ហើយឃុំនៅឆ្ងាយពីផ្លូវធំ ស្ថិតក្នុងក្រុមមានសមត្ថភាពទាប។

ក្នុងករណីនេះ គេអាចសន្និដ្ឋានបានថា ឃុំនៅឆ្ងាយៗ និងពិបាកចូលដល់ តែងចាញ់ប្រៀបគេក្នុងការទទួលបានគម្រោង ហើយតែងត្រូវបានមើលរំលងក្នុងការផ្តល់មូលនិធិ ឬជំនួយទ្រទ្រង់ពីរដ្ឋាភិបាល ឬទីភ្នាក់ងារអភិវឌ្ឍន៍នានា។ ជាលទ្ធផល សមាជិកក្រុមប្រឹក្សាឃុំ/សកម្មជន ក្នុងឃុំដាច់ស្រយាល អាចពុំបានទទួលបទពិសោធន៍ តាមរយៈការអនុវត្តគម្រោងនៅមូលដ្ឋាន។ នេះជាឧបសគ្គរាំងមិនឲ្យពួកគេមានឱកាសធ្វើការពង្រឹងសមត្ថភាព និងកសាងធនធាននៅមូលដ្ឋាន។ ប្រសិនបើសមត្ថភាព និងធនធានរបស់ឃុំពិបាកចូលដល់ នៅតែទន់ខ្សោយ ពួកគេ កាន់តែមិនអាចទាក់ទាញគម្រោងអភិវឌ្ឍន៍សម្រាប់ប្រជាជនមូលដ្ឋាន កុំថាឡើយតែគម្រោងអភិវឌ្ឍន៍ប្រើមូលនិធិពីបរទេសនោះ ជាពិសេសនៅពេលដែលឃុំងាយស្រួលចូលដល់នានា គេកាន់តែមានសមត្ថភាព និងធនធានច្រើនឡើង។ ដូច្នេះ ឃុំទាំងនេះ នឹងកាន់តែផុងជ្រៅទៅក្នុងស្ថានភាពគ្មានសិទ្ធិអំណាច។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដែល (លើកលែងតែឃុំមួយចំនួនតូចចេញ) ទីតាំងភូមិសាស្ត្រ ហាក់មានទំនាក់ទំនងជាមួយ

ក្រាហ្វិក ២. ផែនទីបង្ហាញឃុំនានាតាមចំណាត់ថ្នាក់ CCI



ភាពក្រីក្រ ពោលគឺ ឃុំពិបាកចូលដល់ តែងមានអត្រាភាពក្រីក្រខ្ពស់។

ជាទូទៅ ឃុំអង្កេត មានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់អនុវត្ត។ មូលនិធិសរុបរបស់ឃុំ ពីឆ្នាំ២០០៨ ដល់ ២០១០ តែងមានទំនាក់ទំនងជាមួយនឹងកម្រិតនៃភាពក្រីក្រ។ ឃុំខ្លះទទួលបានហិរញ្ញប្បទានច្រើនជាងឃុំឯទៀត នៅអំឡុងឆ្នាំ២០០៨-១០ ប៉ុន្តែនៅមានអត្រាភាពក្រីក្រខ្ពស់ដដែល។ ឃុំដែលទទួលបានជំនួយពី ADB ហាក់មានសមត្ថភាពប្រសើរជាងឃុំមិនបានទទួលជំនួយសោះ ព្រោះជំនួយនោះបានជួយកែលម្អដល់កត្តាទាំង១០ ដែលបានជ្រើសរើសមកសិក្សា។

មូលនិធិឃុំ/សង្កាត់ មានប្រមាណជា ៥០% នៃមូលនិធិសរុបដែលឃុំអង្កេតទទួលបាន ពីឆ្នាំ២០០៨ ដល់២០១០ ហើយប្រភពមូលនិធិធំបំផុតលំដាប់ទី២ គឺ ADB ដែលបានផ្តល់ហិរញ្ញប្បទានជិត ៣៩% និងបន្ទាប់មកទៀត គឺទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក (DANIDA) ដែលរួមចំណែកជាង ៧%។ ម្ចាស់ជំនួយជាច្រើនទៀត ក៏បានផ្តល់មូលនិធិដល់គម្រោងតូចៗក្នុងឃុំអង្កេតដែរ។

ប្រមាណ៦០%នៃមូលនិធិសរុបរបស់ឃុំអង្កេតបានចំណាយលើគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន ដូចជា ការសាងសង់ និងស្តារ ផ្លូវថ្នល់ ស្ពាន ប្រឡាយ គម្រោងធារាសាស្ត្រ។ល។ ចំណែកធំជាងគេទី២ នៃមូលនិធិរបស់ឃុំ (ប្រមាណ ៣៦%) បានយកទៅប្រើសម្រាប់សកម្មភាពលើកស្ទួយជីវភាពរស់នៅ និងការកែលម្អការគ្រប់គ្រងធនធានធម្មជាតិ ហើយមូលនិធិនៅសល់គឺសម្រាប់សកម្មភាពសង្គម ដូចជា ការអប់រំពីការថែទាំសុខភាពមូលដ្ឋាន (ឧ. ការថែទាំអ្នកជម្ងឺអេដស៍) និងការការពារសិទ្ធិកុមារជាដើម។ លទ្ធផលនេះ បង្ហាញថា មានតែគម្រោងធំជាងគេពីរប៉ុណ្ណោះ (ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងជីវភាពរស់នៅ) ដែលអនុវត្តដោយសមាជិកក្រុមប្រឹក្សាឃុំ។ ដូច្នេះបទពិសោធន៍របស់សមាជិកក្រុមប្រឹក្សាឃុំ ភាគច្រើនទទួលបានតាមរយៈការចូលរួមក្នុងការសម្របសម្រួល និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលប្រើមូលនិធិឃុំ/សង្កាត់ និងការសម្របសម្រួលគំនិតផ្តួចផ្តើមទាក់ទិននឹងជីវភាពរស់នៅ ដែលអនុវត្តដោយភ្នាក់ងារផ្សេងៗទៀត។

ការរចនារៀបចំគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានមន្ត្រីលទ្ធកម្ម និងមន្ត្រីរដ្ឋបាលមូលដ្ឋានថ្នាក់ខ្ពស់ជាង ជួយសម្របសម្រួល ដោយមានគោលការណ៍ណែនាំ នីតិវិធី និងជំនួយបច្ចេកទេសផ្សេងៗ។ ប៉ុន្តែ សមាជិកក្រុមប្រឹក្សាឃុំ ក៏បានផ្តល់ធាតុចូលជាច្រើននៅតាមដំណាក់កាលមួយចំនួនដែរ ដូចជា គំនិត ចំណេះដឹង និងអង្កេតរបស់ពួកគាត់ទាក់ទិននឹងចរាចរណ៍ លំហូរទឹក ត្រី និងសត្វព្រៃជាដើម គឺមានលក្ខណៈសំខាន់ សម្រាប់ការរចនារៀបចំហេដ្ឋារចនាសម្ព័ន្ធ។ សមាជិកក្រុមប្រឹក្សាឃុំ ក៏មានបទពិសោធន៍ក្នុងមូលដ្ឋានយ៉ាងច្រើន ដូចជា ការប្រមូលព័ត៌មានពីអ្នកភូមិ និងការដោះស្រាយទំនាស់ទ្រព្យសម្បត្តិសម្រាប់គ្រួសាររងការប៉ះពាល់ពីគម្រោង ដែលជាធាតុចូលដ៏សំខាន់សម្រាប់ការរចនារៀបចំគម្រោង។ ពាក់ព័ន្ធនឹងគម្រោងលើកស្ទួយជីវភាពរស់នៅ និងសកម្មភាពសង្គមផ្សេងទៀត សមាជិកក្រុមប្រឹក្សាឃុំជួយសម្រេចអារកាត់អំពីគោលដៅនៃគម្រោង រីឯផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ គឺមានជំនួយការ ឬអ្នកសម្របសម្រួលគម្រោង ជួយគ្រប់គ្រង។

ជាទូទៅ ការយល់ដឹងពីបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់ដល់បរិស្ថាន នៅមានកម្រិតនៅឡើយក្នុងចំណោមឃុំអង្កេតនានា។ ការអនុវត្តវិធានការបង្ការគ្រោះធម្មជាតិ ការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថាននាបច្ចុប្បន្ន គេឃើញថា មានការជឿនលឿនខុសៗគ្នា អាស្រ័យលើទីតាំងភូមិសាស្ត្រ កម្រិតនៃការផ្តល់មូលនិធិ និងយុទ្ធសាស្ត្រដោះស្រាយផ្សេងៗគ្នា។

ការងារពាក់ព័ន្ធបញ្ហាសង្គម ជាពិសេសការជម្រុញឲ្យនារី ជនជាតិដើមភាគតិច និងជនប៉ះពាល់ដោយជម្ងឺអេដស៍ បានចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍ និងសកម្មភាពសង្គមនានានោះ មានការជឿនលឿនមិនស្មើគ្នាទេ។ សកម្មភាពទាំងនោះ បានរៀបចំឡើងនៅក្រោមមូលនិធិឃុំ/សង្កាត់ ហើយតែងមានការជម្រុញនៅក្នុងឃុំដោយមូលនិធិទទួលបានបន្ថែមពី អង្គការមិនមែនរដ្ឋាភិបាល។ ទំនាស់អំពីសកម្មភាពចិញ្ចឹមជីវិត និងអំពើហិង្សាក្នុងគ្រួសារ កន្លងមក មានការដោះស្រាយបានល្អ ទោះបីវានៅមានកើតឡើងជារឿយៗក្តី។

## ៥.សេចក្តីសន្និដ្ឋាន

CCI ជាវិធីសាស្ត្រសាមញ្ញ ងាយស្រួល ផ្អែកលើការប្រមូលទិន្នន័យពីការពិភាក្សាក្រុមស្នូល និងសម្រាប់ធ្វើការវាយតម្លៃពីសមត្ថភាពរបស់ អាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍នៅមូលដ្ឋាន និងពីហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងសម្រួលការងារដែលពួកគេមាន។

លទ្ធផលអង្កេតបង្ហាញថា៖

- ឃុំដែលទទួលជំនួយពី ADB ហាក់មានសមត្ថភាព និងអនុវត្តការងារបានប្រសើរជាងឃុំដែលមិនបានទទួល ប៉ុន្តែឃុំដែលទទួលមូលនិធិបានច្រើន មិនប្រាកដថាមានអត្រាភាពក្រីក្រកម្រិតទាបនោះទេ។
- ឃុំពិបាកចូលទៅដល់ ហាក់មានអត្រាភាពក្រីក្រខ្ពស់ ហើយសមត្ថភាព គួបផ្សំគ្នានៃប្រព័ន្ធគ្រប់គ្រងឃុំ និងធនធានមនុស្ស អាចមិនទាន់មានគ្រប់គ្រាន់ សម្រាប់អនុវត្តគម្រោងឲ្យបានសក្តិសិទ្ធិ។
- សមាជិកក្រុមប្រឹក្សាឃុំ បានចូលរួមយ៉ាងច្រើនក្នុងការកសាង និងស្តារហេដ្ឋារចនាសម្ព័ន្ធក៏ពិតមែន ប៉ុន្តែពួកគាត់មិនបានចូលរួមស្មើគ្នាល្អទេ ក្នុងការរចនារៀបចំសកម្មភាពកែលម្អជីវភាព និងអភិវឌ្ឍន៍សង្គម។ ដូច្នេះ ពួកគាត់ទទួលបានសមត្ថភាព ក្នុងការគ្រប់គ្រងគម្រោងហេដ្ឋារចនាសម្ព័ន្ធច្រើនជាង សមត្ថភាពក្នុងការកែលម្អជីវភាពនៅមូលដ្ឋាន ហើយនេះជាបញ្ហាប្រឈមដ៏ធំ សម្រាប់ការធ្វើពិពិធកម្មប្រាក់ចំណូលនៅជនបទ។
- សមាជិកក្រុមប្រឹក្សាជាទូទៅ នៅខ្វះខាតចំណេះដឹង និងការយល់ច្បាស់អំពី បម្រែបម្រួលអាកាសធាតុ ការបង្ការគ្រោះ

តទៅទំព័រ ២៧

អេកូឡូស៊ីសំខាន់ៗចំនួន៤ សម្រាប់គម្រោង "កសិកម្ម និងការប្រែប្រួលអាកាសធាតុ" ដែលជាគម្រោងរួមគ្នាជាមួយ PARD និងទទួលមូលនិធិពីវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI)។ ការសិក្សានេះ ធ្វើវិភាគអំពីកសិកម្ម និងសន្តិសុខស្បៀង ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុក្នុងន័យធំទូលាយ ដោយកំណត់ពីឧបសគ្គក្នុងការលើកកម្ពស់ទិន្នផល និងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ដែលកសិករកំពុងជួបប្រទះនាពេលបច្ចុប្បន្ន។

### កម្មវិធីអភិវឌ្ឍន៍សង្គម (SD)

ក្រុមស្រាវជ្រាវកំពុងអនុវត្តគម្រោងចំនួន ៣។ អត្ថបទកែសម្រួល និងក្របមុខសៀវភៅ "ការលើកកម្ពស់លទ្ធផលក្នុងវិស័យសុខាភិបាល៖ ស្ថាប័ន សន្ទុះចិត្ត និងការលើកទឹកចិត្ត" ខាង ISEAS បានបញ្ជូនមកវិញហើយសម្រាប់ការពិនិត្យជាចុងក្រោយ។ ដោយបានមូលនិធិពីសាកលវិទ្យាល័យស្រាវជ្រាវ (URC) សៀវភៅនេះគឺសម្រាប់ចងក្រង និងផ្សព្វផ្សាយនូវឯកសារស្រាវជ្រាវដែលបានបង្ហាញក្នុងសន្និសីទអន្តរជាតិលើវិស័យសុខាភិបាលរបស់ CDRI កាលពីខែមេសា ២០១០។ សម្រាប់គម្រោងគំនិតផ្តួចផ្តើម EQUITAP[១] ក្រុមស្រាវជ្រាវបានបញ្ជូនលទ្ធផលវិភាគ (លើកលែងការវិភាគអត្ថប្រយោជន៍ ដែលមិនអាចធ្វើបានដោយសារមានទិន្នន័យមិនគ្រប់គ្រាន់) ទៅឲ្យអ្នកសម្របសម្រួល គឺវិទ្យាស្ថានសម្រាប់គោលនយោបាយសុខាភិបាលនៃប្រទេសស្រីលង្ការ។ ក្រោមជំនួយហិរញ្ញវត្ថុពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) គម្រោង EQUITAP បានចប់សព្វគ្រប់នៅចុងខែឧសភា ដោយបានផ្តល់ការវិភាគលើទិន្នន័យអង្កេតគ្រួសារមានស្រាប់ ដើម្បីប៉ាន់ស្មានពីផលប៉ះពាល់ផ្សេងៗដែលធ្វើឲ្យចុះក្រនិងមហន្តរាយ ការវិវត្តទៅមុខ ភាពខុសគ្នាក្នុងការប្រើប្រាស់សេវាថែទាំសុខភាព និងអត្ថប្រយោជន៍ទទួលបានពីចំណាយរដ្ឋាភិបាល។ ក្រុមស្រាវជ្រាវបាននិងកំពុងអនុវត្តគម្រោងស្រាវជ្រាវរយៈពេល ៦ឆ្នាំ ស្តីពី "ការកសាងប្រព័ន្ធសុខាភិបាលសម្រាប់ជនក្រីក្រក្នុងពេលកសាងប្រទេសឡើងវិញ ក្រោយការបញ្ចប់ទំនាស់" ឬហៅកាត់ថា "REBUILD (ការកសាងជាថ្មី)" ដែលទទួលបានមូលនិធិពី ក្រសួងអភិវឌ្ឍន៍អន្តរជាតិអង់គ្លេស (DFID-UK) និងមាន Liverpool School of Tropical Medicine នៃចក្រភពអង់គ្លេស ជួយដឹកនាំ ដើម្បីស្វែងរកភស្តុតាងល្អៗ ជួយរួមចំណែកលើកកម្ពស់សុខភាពប្រជាជនក្រីក្រខ្លាំងក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ នៅឆ្នាំដំបូងនេះ ក្រុមស្រាវជ្រាវនឹងធ្វើការរៀបចំផែនការស្រាវជ្រាវចំនួន ៣៖ ១) ការវិភាគចំណាយរបស់គ្រួសារក្រីក្រលើការថែទាំសុខភាព ២) គ្រឿងលើកទឹកចិត្តសម្រាប់បុគ្គលិកក្នុងវិស័យសុខាភិបាល និង ៣) ការគ្រប់គ្រង និងការអនុវត្តកិច្ចសន្យា។ សិក្ខាសាលាផ្សព្វផ្សាយមួយសម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗ គ្រោងធ្វើឡើងនៅចុងខែមិថុនា។

សកម្មភាពនៃកម្មវិធីបណ្តុះណ្តាលជំនាញកសាងសមត្ថភាពបានចប់សព្វគ្រប់ ហើយរបាយការណ៍ប្រចាំឆ្នាំ បានប្រគល់ជូនម្ចាស់ជំនួយ Oxfam Novib។ ក្រុមបណ្តុះបណ្តាលបានប្តូរទៅខាងផ្នែកគ្រប់គ្រងចំណេះដឹងអភិវឌ្ឍន៍វិញ។

១ EQUITAP ឬ Equity in Asia-Pacific Health System (សមធម៌ក្នុងប្រព័ន្ធសុខាភិបាលនៅអាស៊ីប៉ាស៊ីហ្វិក) ជាកិច្ចប្រឹងប្រែងរួមគ្នារបស់អ្នកស្រាវជ្រាវជាង ១៥ក្រុមនៅអាស៊ី និង អឺរ៉ុប ដើម្បីពិនិត្យពីសមធម៌ក្នុងប្រព័ន្ធសុខាភិបាលជាតិនានានៅអាស៊ីប៉ាស៊ីហ្វិក។ កិច្ចសហការនេះ រួមមាន ការកសាងឧបករណ៍សម្រាប់ស្រាវជ្រាវ និងការវាយតម្លៃជាក់ស្តែងលើការអនុវត្តប្រព័ន្ធសុខាភិបាលជាតិនានា។

*តពីទំព័រ ១៧* **អង្កេតស្តីពីសមត្ថភាព ......**

ធម្មជាតិ និងការគ្រប់គ្រងធនធានធម្មជាតិ។ ការយល់ដឹង និងយុទ្ធសាស្រ្តទប់ទល់របស់ពួកគាត់គួរតែពង្រឹងឡើងតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលអំពី ការសម្របខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ។

### ឯកសារយោង

ADB (2009), "Fact Sheet 2009" (Phnom Penh: ADB)

Blagescu, Minca & John Young (2006), *Capacity Development for Policy Advocacy: Current thinking and approaches among agencies supporting Civil Society Organisations*, Working Paper 260 (London: ODI)

Em Sorany (2008), "Attributes of Knowledge Sharing among Rice Farmers in Ou Saray, Takeo, Cambodia", Master's thesis (Los Banos: University of the Philippines)

Em Sorany & Kim Sour (2011), "The Commune Capacity and Readiness Survey" (Phnom Penh: CDRI)

Kim, N. & R. Henke (2005), "Commune Councils in Cambodia: A National Survey on Their Functions and Performance with Special Focus on Conflict Resolution" (Phnom Penh: Asia Foundation)

Royal Government of Cambodia (2008), "Rectangular Strategy Phase 2" (Phnom Penh: RGC)

Rusten, Caroline, Kim Sedara, Eng Netra & Pak Kimchoeun (2004) "The Challenges of Decentralisation Design in Cambodia", Monograph (Phnom Penh: CDRI)

Tariq H. Niazi (2011), "Sector Study Report on Deconcentration and Decentralisation Reforms in Cambodia: Recommendations for an Institutional Framework" (Metro Manila: ADB)

Thon Vimealea, Ou Sivhuoch, Eng Netra and Ly Tem (2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces*, CDRI Working Paper No. 42 (Phnom Penh: CDRI)

Zulueta, F.M. & Costales, N.E.B. (2006), "Methods of Research Thesis-writing and Applied Statistics", (Metro Manila: Navotas Press)